# វ៉ាក់សាំង COVID-19 ឈ្មោះ Janssen Johnson & Johnson ត្រូវបានអនុញ្ញាត

ct.gov/covidvaccine

Keeping Connecticut Healthy
DPH
Connecticut Department of Public Health

## Food and Drug Administration (FDA, រដ្ឋបាលចំណីអាហារ និងឱសថ) បានចេញការអនុញ្ញាតឲ្យប្រើប្រាស់ពេលអាសន្ន សម្រាប់ វ៉ាក់សាំង COVID-19 ឈ្មោះ Janssen Johnson & Johnson (J&J)។

- នេះមានន័យថា ពេលនេះមានវ៉ាក់សាំង ចំនួនបី ដែលមានសម្រាប់ផ្តល់ជូន (Pfizer-BioNTech, Moderna, និង Johnson & Johnson)។
- វ៉ាក់សាំងទាំងបីគឺ មានសុវត្ថិភាព និង មានប្រសិទ្ធភាពខ្ពស់ ប្រឆាំងនឹងជំងឺ COVID-19 ដែលការពារអ្នកពី៖
  - ✕ ជំងឺធ្ងន់ធ្ងរ
  - ✕ ការសម្រាកព្យាបាល
  - ✕ ការស្លាប់

## ការពិតអំពីវ៉ាក់សាំង ជំងឺ COVID-19 ឈ្មោះ Johnson & Johnson

- តម្រូវឲ្យចាក់តែម្តង មិនមែនពីរដង
- J&J គឺជាវ៉ាក់សាំងវិចទ័រវីរុស។ វ៉ាក់សាំង Pfizer និង Moderna គឺជា វ៉ាក់សាំង mRNA។
- វ៉ាក់សាំងប្រភេទផ្សេងគ្នា ប៉ុន្តែលទ្ធផលដូចគ្នា។ ដូចវ៉ាក់សាំង Pfizer និង Moderna ដែរឬ វ៉ាក់សាំង J&J ៖
  - មិនធ្វើឲ្យនរណាម្នាក់ឆ្លងជំងឺ COVID-19 នោះទេ
  - មិនប៉ះពាល់ ឬមានទំនាក់ទំនងជាមួយ DNA របស់យើងនោះទេ
  - ការពារពីការសម្រាកព្យាបាល និងការស្លាប់ដោយសារជំងឺ COVID-19

## តើវ៉ាក់សាំងមួយណាដែលល្អបំផុតដែលអ្នកអាចទទួលបាន? វ៉ាក់សាំងដែលអ្នកអាចទទួលបាននៅថ្ងៃនេះ។ ប្រសិនបើអ្នកមានសិទ្ធិទទួលបានហើយ សូមកុំរង់ចាំ!

ការទទួលការចាក់វ៉ាក់សាំងគឺជាជំហានមួយក្នុងចំណោមជំហានជាច្រើនដែលអ្នកអាចធ្វើបាន ដើម្បីការពារខ្លួនអ្នក និងអ្នកដទៃពីជំងឺ COVID-19។

សម្រាប់មនុស្សមួយចំនួន ជំងឺ COVID-19 អាចបង្កឲ្យមានជំងឺធ្ងន់ធ្ងរ ឬស្លាប់បាន។ ការទទួលការចាក់វ៉ាក់សាំង មិនត្រឹមតែការពារអ្នកពីជំងឺ COVID-19 ប៉ុណ្ណោះទេ វា ក៏ការពារអ្នកដែលនៅជុំវិញខ្លួនអ្នកផងដែរ តាមរយៈការបង្ការការរីករាលដាលនៃជំងឺនេះ។ ការបញ្ឈប់ជំងឺរាតត្បាតតម្រូវឲ្យមានការប្រើប្រាស់រាល់ឧបករណ៍ដើម្បីបង្ការទាំងអស់ដែលមាន។ វ៉ាក់សាំងធ្វើការជាមួយប្រព័ន្ធភាពស៊ាំរបស់អ្នក ដើម្បីឲ្យរាងកាយរបស់អ្នកនឹងត្រៀមលក្ខណៈរួចរាល់ដើម្បីប្រយុទ្ធនឹងវីរុសនោះ។ ជំហានដទៃទៀត ដូចជាម៉ាស់ និងការរក្សាគម្លាតសង្គម ជួយកាត់បន្ថយឱកាសដែលអ្នកអាចប្រឈមនឹងការឆ្លងវីរុស និងចម្លងវាទៅអ្នកដទៃ។ ជាមួយគ្នា ការចាក់វ៉ាក់សាំងជំងឺ COVID-19 និងការអនុវត្តតាមការណែនាំរបស់ Center for Disease Control (CDC, មជ្ឈមណ្ឌលប្រយុទ្ធប្រឆាំងជំងឺ) ដើម្បីការពារខ្លួនអ្នក និងអ្នកដទៃ នឹងផ្តល់ជូននូវការការពារដ៏ល្អបំផុតពីជំងឺ COVID-19។

ស្វែងយល់បន្ថែម៖
www.fda.gov/media/146305/download

GET THE FACTS ON THE VAX